**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# សេចក្តីថ្លែងការណ៍ របស់លោកតំណាងពិសេសរបស់ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ស្តីពីការប្រើប្រាស់កំលាំងហួសប្រមាណដោយមន្ត្រីប្រតិបត្តិច្បាប់កាលពីថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០២

-ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០០២-

លោកតំណាងពិសេសរបស់ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា មានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការប្រើប្រាស់កំលាំងហួសប្រមាណ បំបែកក្រុមប្រជាពលរដ្ឋ ដែលប្រមូលផ្តុំគ្នាដោយសន្តិភាព នៅក្នុងទីក្រុងភ្នំពេញ កាលពីថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០០២ ។

យ៉ាងហោចណាស់ក៏មានមនុស្ស៧នាក់បានទទួលការព្យាបាលបន្ទាប់ពីកំលាំងនគរបាល និង កងរាជ-អាវុធហត្ថ បានធ្វើឱ្យបែកខ្ញែកដោយហិង្សាលើក្រុមអ្នកតំណាងសហគមន៍ដែលពឹងផ្អែកលើព្រៃឈើ ប្រហែលជា១៥០នាក់ នៅខាងក្រៅនាយកដ្ឋានរុក្ខាប្រមាញ់របស់រដ្ឋាភិបាល ។ អ្នកតំណាងសហគមន៍ទាំងនោះបានកំពុងតែរង់ចាំ ការឆ្លើយតបពីនាយកដ្ឋានទាក់ទងទៅនឹងការចូលរួមរបស់នាយកដ្ឋានក្នុងសិក្ខាសាលាស្តីពីផែនការគ្រប់គ្រង ព្រៃឈើ ។

ដើម្បីបំបែកហ្វូងអ្នកតំណាងសហគមន៍អហិង្សាទាំងនោះ មន្ត្រីប្រតិបត្តិច្បាប់បានវាយ ទាត់ធាក់ និងប្រើដំបងឆក់ ទៅលើ ស្ត្រី និង បុរសដែលបានផ្តុំគ្នានោះ ។ អ្នកតំណាងសហគមន៍ម្នាក់ឈ្មោះ ហែម សៅ អាយុ២៩ឆ្នាំ ជាប្រធានភូមិមកពីខេត្តព្រះវិហារដែលមានវត្តមាននាពេលនោះ បានស្លាប់ពីរទៅបីម៉ោងក្រោយមក ។ ការស្លាប់របស់គាត់នេះត្រូវការរកឱ្យឃើញថា តើមានទាក់ទងទៅនិងការបង្ក្រាបនោះដែរឬទេ ដោយឡែកទាក់ទងទៅនិងការប្រើដំបងឆក់ក្នុងពេលកំពុងមានភ្លៀងធ្លាក់ ។ មានការដឹងយ៉ាងច្បាស់ថា ដំបងឆក់មានសក្តានុភាពធ្វើឱ្យមានរបួសធ្ងន់ធ្ងរ និងស្លាប់តាមរយៈការគាំងបេះដូង ។

ដំបងឆក់ត្រូវបានពង្រាយឱ្យប្រើប្រាស់ដ៏គួរឱ្យកត់សំគាល់នៅក្នុងប្រទេសកម្ពុជាក្នុងពេលដែលអជ្ញាធរធ្វើការបំបែកបាតុកម្មអំឡុងពេលបន្ទាប់ពីការបោះឆ្នោតថ្នាក់ជាតិក្នុងឆ្នាំ១៩៩៨ ។ ការកើតមានឡើងវិញនូវអំពើហិង្សាដែលមានន័យបង្ក្រាបលើហ្វូងប្រជាពលរដ្ឋនោះ គឺជាការគួរឱ្យព្រួយបារម្ភ ជាពិសេសការខិតជិតមកដល់នូវការបោះឆ្នោតថ្នាក់ជាតិក្នុងឆ្នាំ២០០៣ខាងមុខ ។

លោកតំណាងពិសេស សូមអំពាវនាវដល់រដ្ឋាភិបាលកម្ពុជា ចាត់វិធានការដ៏តឹងរឹងទៅលើជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការប្រើប្រាស់កំលាំងហួសប្រមាណនេះ និងសូមឱ្យមានការដាក់បំរាមជាបន្ទាន់ការប្រើប្រាស់ដំបងឆក់ក្នុងគោលបំណងបង្រ្កាបហ្វូងប្រជាពលរដ្ឋ ។

#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១៦A មហាវិថី ម៉ៅ សេទុង សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧